NDIS Quality and Safeguards Commission

NDIS Workforce Capability Framework
Your guide to attitudes, skills and knowledge for NDIS work

# ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS៖ ឧបករណ៍វាយតម្លៃដោយខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល

Khmer | ភាសាខ្មែរ

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS (ក្របខ័ណ្ឌ) ពណ៌នាអំពីអាកប្បកិរិយា ជំនាញ និងចំណេះដឹងដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ដែលបានទទួលមូលនិធិនៅក្រោម NDIS។ វាផ្តល់នូវឧទាហរណ៍ច្បាស់លាស់ និងជាក់ស្តែងមួយចំនួន ហើយបង្កើតជាភាសារួមអំពី 'អ្វីដែលមើលទៅល្អ' សម្រាប់អ្នកចូលរួមទាំងឡាយដែលកំពុងទទួលសេវា និងការគាំទ្រពី NDIS។ ឧបករណ៍នេះគាំទ្រការប្រើប្រាស់ក្របខ័ណ្ឌ ដើម្បីវាយតម្លៃភាពសក្តិសមសម្រាប់ធ្វើការនៅក្នុងវិស័យ NDIS។

ឧបករណ៍វាយតម្លៃដោយខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល អាចគាំទ្រអ្នកស្វែងរកការងារធ្វើលើកដំបូង និងមនុស្សដែលធ្វើការនៅក្រៅវិស័យជនពិការដែលអាចនឹងកំពុងពិចារណាធ្វើការនៅក្នុង NDIS។ ឧបករណ៍នេះប្រើការស្ទង់មតិខ្លីមួយ និងឧទាហរណ៍នានានៃការងារគាំទ្រ ដើម្បីបង្ហាញថាតើការធ្វើការងារនៅក្នុងវិស័យនេះមើលទៅមានលក្ខណៈដូចម្តេចដែរ។

*ការយល់ដឹងអំពីសមត្ថភាព និងជំនាញអ្វីខ្លះដែលត្រូវការពីបុគ្គលិកគាំទ្រ និងថាតើអ្នកមានភាពសក្តិសមល្អឬអត់ គឺជាគន្លឹះក្នុងការសម្រេចចិត្តថាតើតួនាទីនៅក្នុងឧស្សាហកម្មនេះសក្តិសមនឹងអ្នកដែរឬទេ។*

## អ្វីខ្លះដែលនឹងរំពឹងទុក

សំណួរនានាគឺផ្អែកលើគុណភាព និងសមត្ថភាពដែលបានពណ៌នានៅក្នុងក្របខ័ណ្ឌនេះ។

- **រុករក៖** ស្វែងយល់ថាតើការងារក្នុងវិស័យពិការភាពអាចមើលទៅមានលក្ខណៈដូចម្តេចដែរសម្រាប់អ្នក។
- **យល់ដឹង៖** ស្វែងយល់បន្ថែមអំពីជំនាញដែលត្រូវការសម្រាប់ការងារប្រភេទនេះ។
- **ឆ្លុះបញ្ចាំង៖** ផ្នែកទីមួយ ពិនិត្យមើលឥរិយាបថ និងគុណតម្លៃរបស់អ្នក។ អ្នកនឹងត្រូវបានសួរឱ្យវាយតម្លៃថាតើអ្នកយល់ស្រប ឬមិនយល់ស្របខ្លាំងប៉ុណ្ណាដែរជាមួយនឹងសេរីនៃសេចក្តីថ្លែងមួយចំនួន។

- **ពិចារណា៖** អ្នកនឹងអានឧទាហរណ៍នានានៃស្ថានភាពគាំទ្រដែលកើតឡើងនៅពេលធ្វើការក្នុងវិស័យជនពិការ ហើយជ្រើសរើសសកម្មភាពណាដែលអ្នកនឹងធ្វើចេញពីបណ្តាជម្រើសពហុជម្រើស។ អ្នកក៏នឹងត្រូវបានសួរដែរថា តើសេណារីយ៉ូនេះបានធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងណាដែរ។
- **រៀនសូត្រ៖** ផ្នែកទីបី ស្នើឱ្យអ្នកបញ្ចូលព័ត៌មានអំពីបទពិសោធន៍រស់នៅ និងបទពិសោធន៍ការងាររបស់អ្នក ដែលអាចពាក់ព័ន្ធនឹងការធ្វើការងារនៅក្នុងវិស័យពិការភាព។
- **សម្រេចចិត្ត៖** ចូលប្រើលទ្ធផលរបស់អ្នក និងការណែនាំទូទៅអំពីជំហានបន្ទាប់ ដើម្បីជួយអ្នកក្នុងការសម្រេចចិត្តរបស់អ្នក។

NDIS Quality and Safeguards Commission

NDIS Workforce Capability Framework
Your guide to attitudes, skills and knowledge for NDIS work

## ឧបករណ៍ក្នុងការអនុវត្ត៖

Abeni ចាប់អារម្មណ៍លើអាជីពក្នុងវិស័យពិការភាព ប៉ុន្តែនាងមិនប្រាកដថាអ្វីដែលនឹងរំពឹងទុក ឬគុណវុឌ្ឍិ និងជំនាញអ្វីខ្លះដែលនាងត្រូវការនោះទេ។ នាងប្រើ **ឧបករណ៍វាយតម្លៃដោយខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល** ហើយជាពិសេសចូលចិត្តសេណារីយ៉ូ ដែលផ្តល់ឱ្យនាងនូវគំនិតកាន់តែប្រសើរឡើងអំពីប្រភេទការងារដែលនាងអាចធ្វើបាន។ ការវាយតម្លៃប្រាប់នាងថា នាងមានឥរិយាបថ គុណតម្លៃ និងជំនាញនានាដែលអស្ចារ្យសម្រាប់ការងារគាំទ្រ។

ឧបករណ៍នេះក៏ណែនាំផងដែរអំពីការបណ្តុះបណ្តាលបន្ថែមអ្វីខ្លះ ឬឱកាសដែល Abeni អាចស្វែងរកដើម្បីជួយនាងក្នុងការស្វែងរកការងារនៅក្នុងវិស័យនេះ និងរបៀបដែលនាងអាចអនុវត្តជំនាញបច្ចុប្បន្នរបស់នាងនៅក្នុងតួនាទីថ្មីមួយ។ ឥឡូវនេះគឺច្បាស់លាស់ហើយអំពីការអភិវឌ្ឍន៍អ្វីខ្លះដែលនាងនឹងត្រូវការ និងប្រភេទការងារដែលនាងអាចដាក់ពាក្យសុំបាន, Abeni ប្រើប្រាស់ **សៀវភៅមគ្គុទេសក៍ជម្រើសអាជីព** ដើម្បីស្វែងយល់បន្ថែមអំពីភាពខុសពីគ្នានៃតួនាទីនានាដែលនាងអាចធ្វើបាន ហើយចាប់ផ្តើមផែនការមួយសម្រាប់ការបង្កើតអាជីពនៅក្នុងវិស័យគាំទ្រពិការភាព។

## ការចូលប្រើប្រាស់ និងការប្រើប្រាស់ឧបករណ៍

ឧបករណ៍វាយតម្លៃដោយខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល អាចប្រើប្រាស់បានយ៉ាងល្អបំផុតនៅតាមអនឡាញ ទោះបីជាយ៉ាងណាក្តី មានឧបករណ៍កំណែឯកសារ Word ដែលអាចទាញយកបាន និងអាចចូលប្រើបានផងដែរ។

អ្នកអាចធ្វើការវាយតម្លៃច្រើនដងតាមដែលអ្នកចង់ ហើយប្រសិនបើអ្នកចង់រក្សាទុកលទ្ធផលរបស់អ្នកដើម្បីយោងនៅពេលក្រោយ អ្នកអាចផ្ញើតំណភ្ជាប់ទៅកាន់លទ្ធផលដែលបានបញ្ចប់របស់អ្នកតាមរយៈអ៊ីមែល នៅពេលដែលអ្នកបានបញ្ចូលព័ត៌មានដែលត្រូវការទាំងអស់។ អ្នកផ្តល់សេវាអាចប្រើឧបករណ៍នេះជាផ្នែកនៃការវាយតម្លៃរបស់ពួកគេអំពីបុគ្គលិកដែលមានសក្តានុពល។

**ចូលប្រើឧបករណ៍៖** ឧបករណ៍វាយតម្លៃដោយខ្លួនឯងសម្រាប់បុគ្គលិកដែលមានសក្តានុពល | សមត្ថភាពកម្លាំងពលកម្ម NDIS ( ndiscommission.gov.au )

សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌ ឬការអនុវត្តរបស់សៀវភៅមគ្គុទ្ទេសក៍នេះ សូមចូលមើលគេហទំព័រ៖ https://workforcecapability.ndiscommission.gov.au/។

**ទំនាក់ទំនង៖** contactcentre@ndiscommission.gov.au ឬ 1800 035 554។